សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៤

ចុះថ្ងៃទី ១០_០១_២០១០

សាលដីកា

លេខ : ៧២ "ខ"

ចុះថ្ងៃទី ២៣_០៧_២០១០

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣_០៧_២០១០ ដោយមានសមាសភាពដូចខាងក្រោម:

ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៤ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១០ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកោះកាពិ ឃុំកោះកាពិ ស្រុកគីរីសាគរ ខេត្តកោះកុង ទីលំនៅសព្វថ្ងៃ[redacted]ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរគូកជេររថយន្ត ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ២នាក់ ទោសពីមុនគ្មាន ។

មានលោក [redacted] ជាមេធាវីការពារជនជាប់ចោទ ។

<u>ជាប់ចោទពីបទ:</u> ប្លន់ (គាស់សោររថយន្តយកសម្ភារ:) ប្រព្រឹត្តនៅបរិវេណទីស្តីការគណ:រដ្ឋមន្ត្រី កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គាន ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរអនុប្រធាននាយកដ្ឋានបុគ្គលិក ទីលំនៅសព្វថ្ងៃផ្ទះលេខ ៧១E0 ផ្លូវលេខ ១២៨ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៣៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្រុស ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ ៣ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## ងដំណើររឿងមានដូចតទៅ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]កាន ថា កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ ត្រង់ចំណុចក្នុងបរិវេណទីស្តីការគណៈរដ្ឋមន្ត្រីមានជនមិនស្គាល់ឈ្មោះបានប្រព្រឹត្តសកម្មភាពលួចគាស់ទ្វាររថយន្ត របស់ខ្លួន ដែលខ្លួនចូលរួមប្រជុំចាប់ពីម៉ោង ៨ និង៣០នាទី រហូតដល់ម៉ោង ១១ និង២០នាទី លុះចប់កម្មវិធីប្រជុំ ខ្លួនបាន ចេញមកវិញដើរសំដៅទៅរថយន្ត ទើបដឹងថាមានចោរលួចគាស់ទ្វាររថយន្ត។ សម្ភារៈដែលបាត់បង់មាន ទូរស័ព្ទចំនួន ២គ្រឿង IDលេខ ៧៥៤៧៤២ ប័ណ្ណប្រេងសូតឹម៉ិចចំនួន ២០០លីត្រ ប័ណ្ណប្រេងតេលាចំនួន ១៦០លីត្រ ប្រាក់ចំនួន ១០០ដុល្លា និងប្រាក់រៀលចំនួន ៨.០០០.០០០រៀល ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ ៣ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូង រាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៧ឆ្នាំ (ប្រាំពីរឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០០៩ ពីបទ ប្លន់ (គាស់សោររថយន្តយកសម្ភារៈ) ប្រព្រឹត្តនៅ បរិវេណទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- បង្គាប់ឱ្យឈ្មោះ [redacted]ប្រុស សងទ្រព្យសម្បត្តិដែលបានបាត់បង់រួមមាន:

- ID មួយគ្រឿងម៉ាក (MTX ៨០០)
- ទូរស័ព្ទម៉ាក LG មួយគ្រឿង
- ប័ណ្ណប្រេង Sokimex ចំនួន ២សន្លឹក ស្មើនឹង ២០០លីត្រ
- ប័ណ្ណប្រេង Tela ចំនួន ៤សន្លឹក ស្មើនឹង ១១០លីត្រ
- ប្រាក់ដុល្លាចំនួន ១០០ដុល្លា (មួយរយដុល្លាអាមេរិក)
- ប្រាក់ខ្មែរចំនួន ៨.០០០.០០០រៀល (ប្រាំបីលានរៀល)

ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]កាន នៅពេលសាលក្រមចូលជាស្ថាពរ ។

៣- ច្រានចោលការទាមទារជម្ងឺចិត្តពីជនជាប់ចោទឈ្មោ[redacted]ប្រុស ។

៤- វត្ថុតាងមានដូចក្នុងកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៩ របស់តំណាងអយ្យការ រួមមាន:

ក- ប័ណ្ណប្រេងសាំងតេលាចំណុះ ៥០លីត្រ និងទូរស័ព្ទដៃម៉ាកសាំសុងស៊ុមពីរ សេរី D.M.B ចំនួនមួយគ្រឿង ប្រគល់ឱ្យម្ចាស់ដើមវិញតាមដីកាសម្រេចលេខ ៧៧៣៦ ត.ព្រ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។

ខ- ដែកមុខរាងអក្សរ V ដងខ្មៅចំនួនមួយ រឹបអូសបំផ្លាញចោល ។

៥- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៣៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្រុស ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ ៣ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កាន បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

ជនជាប់ចោទឈ្មោះ [redacted] ប្រុស ឆ្លើយថាៈ ខ្លួនមិនសុខចិត្ត ដោយប៉ូលីសចាប់ចោទពីបទ ចោរកម្ម ហើយតុលាការបែរជាសម្រេចចោទពីបទ ប្លន់ វិញ ។ ខ្លួនមិនបានគាស់ទ្វារឡានទេ គឺឡានអត់មានចាក់សោរទេ ហើយកន្លែងចតឡាននោះស្ងាត់ ឡានចេញចូលផ្លូវផ្សេង ហើយមិនមានមនុស្សដើរទេ ខ្លួនក៏បានចូលយកសម្ភារៈក្នុងឡាន ។ ចំពោះដែកអក្សរ V គឺដែកនៅក្នុងឡានរបស់ខ្លួន តែខ្លួនពិតជាមិនបានគាស់ទ្វារឡានទេ ។ នៅថ្ងៃកើតហេតុនោះពេលខ្លួនត្រឡប់មកពី បត់ជើងតូចវិញ ខ្លួនឃើញឡានរបស់ [redacted] កាន ដែលចតនៅជិតឡានខ្លួនមានភ្លើងក្រហមលោត ហើយឡានអត់មានចាក់សោរទេ ហើយប្រសិនបើខ្លួនគាស់ទ្វារឡានមែន ប្រព័ន្ធតេឡេស្វ័យប្រវត្តិក្នុងឡាននឹងបន្លឺសម្លេងឡើងហើយ ព្រោះឡាននោះជាប្រភេទឡានហាយឡិនដឺរ ឆ្នាំ២០០៣ ។ កន្លងមកខ្លួនមិនដែលប្រព្រឹត្តអំពើនេះទេ ។ ចម្ងាយពីកន្លែងខ្លួនចតឡានទៅកន្លែងសន្តិសុខយាមប្រហែល ១៥ម៉ែត្រ ។ ខ្លួនយកលុយខ្មែរបាន ៣លានរៀល និងទូរស័ព្ទ ១គ្រឿង និងប៉ុងសាំង ១០០លីត្រ ។ លុយ ខ្មែរខ្លួនបានចាយអស់ ឯលុយដុល្លាមិនមានទេ ។ សំណូមពរ សុំមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានសួរដេញដោល និងតាមចម្លើយសារភាពរបស់ជនជាប់ចោទ សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើចំណុចថាគាត់មិនបានគាស់ទ្វារឡានទេ ប៉ុន្តែ ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ។ ដូច្នេះ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា និងសម្រេចតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

កូនក្តីខ្លួនបានឆ្លើយសារភាពថាបានលួចសម្ភារៈក្នុងឡានមែន តែមិនបានគាស់ទម្លុះទម្លាយទេ គឺដោយសារម្ចាស់ឡានមានការធ្វេសប្រហែស ។ ចំពោះបទល្មើសប្លន់ គឺប្រព្រឹត្តចាប់ពី ២នាក់ ឡើងទៅ ។ ចំពោះដែកអក្សរ V កូនក្តីខ្លួនបានអះអាងថាជាដែកសម្រាប់គាស់កង់ឡាន ដែកនេះមិនអាចយកទៅគាស់សោរបានទេ ។ ដូចនេះ សូមតុលាការមេត្តាកែប្រែបទចោទ ពីបទ ប្លន់ ទៅជា បទ ចោរកម្ម វិញ និងសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ**

១- បណ្តឹងឧទ្ធរណ៍លេខ ៦៣៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្រុស ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ ខ្លួនបានជូនឈ្មោះ [redacted] ថា ហៅ ឌីណា ទៅទីស្តីការគណៈរដ្ឋមន្ត្រី ពេលទៅដល់ឈ្មោះ [redacted] ថា ឡើងទៅលើទីស្តីការ ឯខ្លួននៅអង្គុយចាំនៅក្នុងរថយន្តម៉ាក LEXUS RS ៣០០ របស់ឈ្មោះ [redacted] ថា ក្រោយមកខ្លួនដើរទៅនោមឃើញភ្លើងក្រហមក្នុងរថយន្តម៉ាកហាយឡិនដឹរ លោតភ្លែត១ដោយអត់ចាក់សោរ ខ្លួនក៏បើកទ្វារមុខខាងឆ្វេងចូលទៅយករបស់របរក្នុងរថយន្តនោះដោយមិនបានគាស់ទម្លុះ ទម្លាយសោរឡាននោះឡើយ ហេតុនេះហើយបានជាសម្លេងស៊ីរ៉ែននៃសោរទូបញ្ជាដែលដាក់ភ្ជាប់នឹងឡាននោះមិនស្រែក បន្លឺឡើងទេ ។

ពេលខ្លួនបើកទ្វារឡានចូលយករបស់នៅក្នុងឡាននោះខ្លួនធ្វើតែម្នាក់ឯងទេ គ្មានគូកនបក្សពួកចូលរួមឡើយ ។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ (គាស់ទ្វាររថយន្ត) ប្រព្រឹត្តនៅក្នុងបរិវេណនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

៤- ជនជាប់ចោទទើបតែប្រព្រឹត្តអំពើល្មើសជាលើកទី ១ ហើយបានឆ្លើយសារភាពថា ខ្លួនពិតជាបានចូលយករបស់ទ្រព្យរបស់ជនរងគ្រោះនៅក្នុងឡានជនរងគ្រោះប្រាកដមែន ហើយសច្ចារាងចាលលែងប្រព្រឹត្តទៀតហើយ សុំឱ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសដើម្បីបានកែខ្លួនឱ្យបានជាមនុស្សល្អក្នុងសង្គមវិញ ។ សាលាឧទ្ធរណ៍គួរពិចារណាចំពោះសំណើសុំនេះ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ ៣ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ តែគួរកែប្រែកម្រិតទណ្ឌកម្មឱ្យបានសមស្រប ដោយហេតុដូចបានយល់ឃើញខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦៣៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្រុស ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ ៣ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ តែកម្រិតទណ្ឌកម្មត្រូវកែទៅជា ៥ឆ្នាំ ( ប្រាំឆ្នាំ) វិញ ក្រៅពីនេះទុកនៅដដែល ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ៕

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៤ ខែ ៧ ឆ្នាំ២០១០

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]